# សំណួរដែលសួរញឹកញាប់ អំពីសត្វសង្កើច



**តើសត្វសង្កើចជាអ្វី?**
សត្វសង្កើចគឺជាសត្វល្អិតដែលស៊ីឈាមមនុស្សនិងសត្វ។ ពួកវាមានរាងតូច សំប៉ែត ពណ៌ត្នោត និងមូលទ្រវែង។ ពួកវាគ្មានស្លាបទេ។

**តើសត្វសង្កើចមានរូបរាងដូចម្តេច?**

- ពងសង្កើចមានពណ៌ស និងមានរាងដូចផ្លែសារី។ នៅពេលពួកវាញាស់ដំបូង សត្វសង្កើចមានពណ៌ស្រាល និងថ្លា។ នៅពេលវាធំឡើង ពួកវាមានពណ៌ត្នោតកាន់តែខ្លាំង។

- សត្វសង្កើចពេញវ័យ មានពណ៌ត្នោតក្រហម សំប៉ែត និងរាងទ្រវែង។ ប្រសិនបើអ្នកមើលឱ្យជិត អ្នកអាចឃើញរោមខ្លីៗពណ៌មាស។ សត្វសង្កើចគ្មានស្លាបទេ។ ពួកវាមានក្លិនឆ្អេះឈ្ងល។ បន្ទាប់ពីពួកវាស៊ីរួច ពួកវាឡើងប៉ោង និងមានពណ៌ក្រហមចាស់។

**ហេតុអ្វីបានជាសត្វសង្កើចក្លាយជាបញ្ហា?**
សត្វសង្កើចកំពុងតែក្លាយជាបញ្ហាខ្លាំងឡើងនៅក្នុងទីក្រុងនិងទីប្រជុំជនជាច្រើន។ នេះប្រហែលជាដោយសារតែមនុស្សកាន់តែច្រើនឡើងកំពុងធ្វើដំណើរចេញក្រៅប្រទេសទៅកាន់ទីកន្លែងដែលសត្វសង្កើចមានបញ្ហា។ ក៏ប្រហែលជាដោយសារតែថ្នាំសម្លាប់សត្វល្អិតជាក់លាក់សម្រាប់ការរីករាលដាលនៃសត្វសង្កើច ត្រូវបានហាមឃាត់។

**តើសត្វសង្កើចចូលទៅកាន់លំនៅដ្ឋានរបស់មនុស្សដោយរបៀបណា?**
ជាធម្មតា សត្វសង្កើចចូលទៅកាន់លំនៅដ្ឋានរបស់អ្នកតាមរយៈឥវ៉ាន់ សម្លៀកបំពាក់ និងរបស់របរផ្ទាល់ខ្លួនផ្សេងទៀតនៅអំឡុងពេលធ្វើដំណើរ។ ជួនកាល សណ្ឋាគារមានសត្វសង្កើច។ សត្វសង្កើចអាចវារចូលទៅក្នុងឥវ៉ាន់ ហើយត្រូវបានយកចូលទៅកាន់លំនៅដ្ឋានរបស់អ្នក។ សត្វសង្កើចតែមួយប៉ុណ្ណោះ អាចធ្វើឱ្យការរីករាលដាលនៃសត្វសង្កើចចាប់ផ្តើមឡើងនៅផ្ទះរបស់អ្នក។

សត្វសង្កើចក៏អាចចូលទៅក្នុងផ្ទះរបស់អ្នកដោយការវារទៅលើសម្លៀកបំពាក់របស់អ្នកផងដែរ ប៉ុន្តែនេះពុំសូវកើតមានទេ។ លក្ខណៈទូទៅភាគច្រើនក្នុងការនាំយកសត្វសង្កើចទៅក្នុងផ្ទះរបស់អ្នក គឺក្នុងករណីអ្នកទិញនិងស្លៀកសម្លៀកបំពាក់ជជុះ ឬគ្រឿងសង្ហារឹមប្រើប្រាស់រួចដែលមានសត្វសង្កើចនៅក្នុងនោះ។

**តើមានវិធានការដែលខ្ញុំអាចអនុវត្តដើម្បីជៀសវាងការនាំយកសត្វសង្កើចចូលទៅក្នុងផ្ទះរបស់ខ្ញុំបានដែរឬទេ?**
មាន អ្នកគួរតែពិនិត្យមើលគ្រឿងសង្ហារឹមឱ្យបានច្បាស់មុនពេលនាំយកវាទៅផ្ទះ។

ពិនិត្យមើលអាផាតមិន និងបន្ទប់គេង។ ការរស់នៅក្នុងទីកន្លែងបួនជ្រុងបិទជិត អាចបង្កឱ្យមានសត្វសង្កើចបានដោយងាយ។ ពួកវាតែងរស់នៅក្នុងកន្លែងចន្លោះជញ្ជាំង។ ប្រសិនបើអាផាតមិនមួយនៅក្បែរអាផាតមិនរបស់អ្នកមានសត្វសង្កើចនោះ អ្នកក៏អាចនឹងមានពួកវាដែរ។ មានការពិបាកដោះស្រាយបញ្ហាសត្វសង្កើចណាស់ រហូតទាល់តែអាផាតមិនទាំងអស់នៅក្នុងអគារនោះចាត់វិធានការដើម្បីកម្ចាត់ពួកវា។

ត្រួតពិនិត្យអាផាតមិនដែលទំនេររកមើលសត្វសង្កើចមុនពេលចូលមករស់នៅ។ សត្វសង្កើចអាចមានជីវិតរស់នៅជាច្រើនខែដោយមិនស៊ីចំណី។

**តើសត្វសង្កើចលាក់ខ្លួននៅកន្លែងណា?**

- គ្រែ (ថ្នេរ កញ្ចុំ និងស្នាមប្រេះនៃពូកនិងរឺស័រប្រអប់) គ្រោងគ្រែ ក្បាលគ្រែ និងនៅក្នុងវត្ថុរាយប៉ាយក្រោមគ្រែ
- កម្រាល និងបាតជញ្ជាំង
- ខាងក្រោយក្រដាសបិទជញ្ជាំងមានចន្លោះចំហ
- ផ្ទត់វាំងនន និងរនាំងសំពត់
- នាឡិកាព្យួរជញ្ជាំង វិទ្យុ ឬទូរស័ព្ទដែលនៅជិតគ្រែ ឬនៅលើតុក្បាលគ្រែ
- ខាងក្នុងនិងក្រោមថតតុ
- ស៊ុមរូបថត

**តើសញ្ញានៃការរីករាលដាលនៃសត្វសង្កើចមានអ្វីខ្លះ?**
សញ្ញានៃការរីករាលដាលនៃសត្វសង្កើចអាចមានដូចជា៖

- ស្នាមអុចឬស្នាមប្រឡាក់ខ្មៅៗ (ក្រហម ឬត្នោត) នៅលើកម្រាលពូក ស្រោមខ្នើយ ឬពូក ឬកន្លែងក្បែរនោះដែលបណ្តាលមកពីអាចម៍សត្វសង្កើច។
- ក្លិនឆ្អេះខុសពីធម្មតា
- កន្ទួលរមាស់តូចៗពណ៌ក្រហមនៅលើស្បែករបស់អ្នកដែលបណ្តាលមកពីសត្វសង្កើចខាំ

**តើមានអ្វីកើតឡើងបើសត្វសង្កើចខាំខ្ញុំ?**
គេមិនដឹងថាសត្វសង្កើចចម្លងជំងឺឆ្លងនោះទេ។ ការខាំរបស់ពួកវា មានសភាពដូចជាសត្វល្អិតជញ្ជក់ឈាមភាគច្រើនដែរ និងអាចបណ្តាលឱ្យមានការរោលលើស្បែកខ្លះៗ។ ការខាំមួយចំនួនអាចនឹងមិនត្រូវបានកត់សម្គាល់នោះទេ ចំណែកការខាំខ្លះទៀតប្រែទៅជាដំបៅក្លាយកាន់តែធំឡើង។

**តើខ្ញុំអាចព្យាបាលសង្កើចខាំបានដូចម្តេច?**
លាងសម្អាតកន្លែងខាំដោយប្រើសាប៊ូសម្លាប់មេរោគដើម្បីកាត់បន្ថយការឆ្លងមេរោគ និងទប់ស្កាត់កុំឱ្យចេះតែចង់អេះរមាស់។ ទាក់ទងទៅកាន់អ្នកផ្តល់សេវាសុខភាពរបស់អ្នក ប្រសិនបើការខាំនោះឆ្លងមេរោគ។

**តើខ្ញុំកម្ចាត់សត្វសង្កើចយ៉ាងដូចម្តេច?**
ប្រសិនបើអ្នកឃើញសញ្ញានៃការរីករាលដាលនៃសត្វសង្កើចអ្នកគួរតែមើលឱ្យបានច្បាស់គ្រប់ផ្នែកទាំងអស់នៃផ្ទះរបស់អ្នកដើម្បីរកមើលថាតើអ្នកមានសត្វសង្កើចដែរឬទេ។

- កំណត់ប្រភពដើម។
- ប្រើម៉ាស៊ីនបូមធូលី (យកល្អត្រូវមានតម្រង HEPA) ដើម្បីកម្ចាត់សត្វល្អិត និងសំណករបស់ពួកវាចេញពីគ្រប់កន្លែងដែលអ្នកឃើញពួកវា ឬគិតថាពួកវាអាចនៅទីនោះ។ ធ្វើដូចនេះនៅអំឡុងពេលត្រួតពិនិត្យដំបូង និងយ៉ាងហោចណាស់រៀងរាល់សប្តាហ៍នៅពេលក្រោយមកទៀត។
- បោះចោល ឬជូត និងបូមសម្អាតពូក បន្ទាប់មករុំពូកក្នុងស្រោមពូកដែលមានខ្សែរ៉ូត។ លាងសម្អាតក្បាលគ្រែ និងគ្រោងគ្រែ។
- ប្រើប្រាស់ការបិទភ្ជិតស្នាមដែលមានជាតិស៊ីលីខូនមានគុណភាពខ្ពស់។ បិទភ្ជិតរាល់ស្នាមប្រេះ ស្នាមចំហ និងចំណុចច្រកចូលនៅក្នុងជញ្ជាំង ជាពិសេសក្នុងកម្ពស់ 20 ហ្វីតនៃកន្លែងដែលមានសង្កើចខាំ។
- មិនត្រូវប្រើថ្នាំសម្លាប់សត្វល្អិតណាមួយដោយខ្លួនឯងនោះទេ។ វានឹងរឹតតែធ្វើឱ្យមានការរីករាលដាលកាន់តែខ្លាំងឡើង។
- ទាក់ទងទៅកាន់ប្រតិបត្តិករផ្នែកកម្ចាត់សត្វល្អិតចង្រៃដែលមានអាជ្ញាប័ណ្ណ។
- នៅពេលដែលសម្លៀកបំពាក់ (ឧ.ទា. ស្រោមខ្នើយ-ពូក ខោអាវ ។ល។) ត្រូវបានបោកគក់ សូមទុកពួកវានៅក្នុងថង់ប្លាស្ទិកធំៗ ឬធុងបិទជិត ដើម្បីបង្ការកុំឱ្យមានការរីករាលដាលសាជាថ្មី។
- ញែករវត្ថុដែលបានសម្អាត (គ្មានសត្វសង្កើច) នៅដាច់ដោយឡែក រហូតដល់អស់សត្វសង្កើច។

**តើនរណាទទួលខុសត្រូវកម្ចាត់សត្វសង្កើច?**
ករណីភាគច្រើន ម្ចាស់ផ្ទះ ឬអ្នកគ្រប់គ្រងអចលនទ្រព្យត្រូវបានច្បាប់តម្រូវឱ្យ "ថែរក្សាលំនៅដ្ឋាន និងបរិវេណទីតាំងកុំឱ្យមានការីករាលដាល ហើយត្រូវទទួលខុសត្រូវចំពោះការកម្ចាត់សត្វល្អិតចង្រៃ" (MA: 105 CMR 410.550)។ ម្ចាស់ផ្ទះមានទំនួលខុសត្រូវឆ្លើយតបទៅនឹងការប្តឹងតវ៉ាអំពីសត្វសង្កើច។

ប្រសិនបើនរណាម្នាក់កំពុងជួលលំនៅដ្ឋានដែលមានបន្ទប់ស្នាក់នៅជាមួយ ម្ចាស់ផ្ទះអាចនឹងមិនទទួលខុសត្រូវចំពោះការសម្លាប់សត្វល្អិតឱ្យអស់នោះទេ ដរាបណាពួកគេរក្សាការថែទាំផ្ទះ។ នៅក្នុងករណីទាំងនេះ អ្នកកាន់កាប់អាចនឹងចាំបាច់ត្រូវបង់ប្រាក់។

ប្រសិនបើអ្នកជាអ្នកជួលផ្ទះ សូមទាក់ទងទៅកាន់ម្ចាស់ផ្ទះរបស់អ្នកដើម្បីឱ្យពួកគេអាចជួលអ្នកកម្ចាត់សត្វល្អិតដែលមានអាជ្ញាប័ណ្ណដើម្បីកំណត់អត្តសញ្ញាណសត្វល្អិត និងបង្កើតផែនការកម្ចាត់សត្វល្អិត ឬផែនការ IPM (ការគ្រប់គ្រងសត្វល្អិតចង្រៃរួមបញ្ចូលគ្នា) ដើម្បីលុបបំបាត់ពួកវា។

**ទំនួលខុសត្រូវរបស់ម្ចាស់ផ្ទះ ឬម្ចាស់អចលនទ្រព្យ**
លើកទឹកចិត្តអ្នកជួលឱ្យរាយការណ៍អំពីសត្វសង្កើច។ ឆ្លើយតបយ៉ាងឆាប់រហ័សចំពោះការប្តឹងតវ៉ាដោយមានការត្រួតពិនិត្យ និងអន្តរាគមន៍។

**ទំនួលខុសត្រូវរបស់អ្នកស្នាក់នៅ**

- អនុវត្តតាមការណែនាំសម្រាប់ការរាយការណ៍អំពីសត្វសង្កើច។
- សហការជាមួយបុគ្គលិកក្នុងការកម្ចាត់សត្វសង្កើច។

## តើខ្ញុំអាចទាក់ទងនរណាដើម្បីទទួលបានព័ត៌មានបន្ថែម?

ក្រុមប្រឹក្សាសុខភាពក្នុងតំបន់របស់អ្នក ឬ៖


**Bureau of Climate and Environmental Health**
**MA Department of Public Health**
250 Washington Street, 7th Floor, Boston, MA 02108
ទូរស័ព្ទ៖ 617-624-5757 | ទូរសារ៖ 617-624-5777 | TTY: 617-624-5286
www.mass.gov/dph/environmental_health



ខែតុលា ឆ្នាំ 2023